**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋាន សញ្ញាស័ក្តិ និងសញ្ញាសម្គាល់របស់ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតឯកសណ្ឋាន សញ្ញាស័ក្តិ និងសញ្ញាសម្គាល់សម្រាប់ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ឯកសណ្ឋានរួមមាន ឯកសណ្ឋានផ្លូវការ និងឯកសណ្ឋានប្រពៃណីជាតិ ។

សញ្ញាស័ក្តិរួមមាន ស័ក្តិចុងកអាវ ស័ក្តិស្មា ស័ក្តិចុងដៃអាវទាំងសងខាង សម្រាប់ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

ឯកសណ្ឋាន និងសញ្ញាស័ក្តិនេះ ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ ។

**មាត្រា ៣ .-**

សញ្ញាសម្គាល់ជាផ្លូវការរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ គឺមានរូបសញ្ញាសាលាក្រុង ស្រុក ខណ្ឌ ដោយមានផ្ទៃខាងក្រោយពណ៌បៃតង ព័ទ្ធជារង្វង់ដោយក្លួរស្រូវពណ៌មាស ភ្ជាប់ដោយខ្សែបូ អមដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស។

សញ្ញាសម្គាល់ជាផ្លូវការរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានគំរូដូចក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## អំពីសញ្ញាស័ក្តិ

**មាត្រា ៤ .-**

សញ្ញាស័ក្តិសម្រាប់សម្គាល់ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានកំណត់ដូចខាងក្រោម ៖

**ក-សញ្ញាស័ក្តិចុងកអាវ**

**១-សម្រាប់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ**

សញ្ញាស័ក្តិចុងកអាវ សម្រាប់សម្គាល់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានផ្ទៃកម្រាលពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់ក្លួរស្រូវពណ៌មាស និងក្បាច់សន្លឹកភ្ញីទេសពណ៌មាសដាក់ខ្វែងគ្នា ហើយមានរូបសញ្ញាសាលាក្រុង ស្រុក ខណ្ឌ ពណ៌មាសនៅពីខាងមុខ ។ បន្ទាប់មកមានបន្ទះក្បាច់ធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញ និងមានខ្សែពួរវេញពណ៌មាស នៅផ្នែកខាងលើភ្ជាប់ជាមួយចំហៀងខាងមុខបីជាន់ ។

**២-សម្រាប់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ**

សញ្ញាស័ក្តិចុងកអាវសម្រាប់សម្គាល់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានសណ្ឋានដូចសញ្ញាស័ក្តិចុងកអាវរបស់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌដែរ ប៉ុន្តែខុសគ្នាត្រង់សញ្ញាស័ក្តិចុងកអាវសម្គាល់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានពណ៌ប្រាក់ និងមានក្បាច់ខ្សែពួរវេញពណ៌ប្រាក់ព័ទ្ធជុំវិញពីរជាន់ ។

**ខ្នាតសញ្ញាស័ក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោម ៖**

-មានរាងជាប្រលេឡូក្រាម

-បណ្តោយប្រវែង ១១សង់ទីម៉ែត្រ

-ទទឹងប្រវែង ០៤សង់ទីម៉ែត្រ ។

**ខ-សញ្ញាស័ក្តិស្មា**

**១-សម្រាប់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ**

សញ្ញាស័ក្តិស្មា សម្រាប់សម្គាល់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានផ្ទៃកម្រាលពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់ក្លួរស្រូវពណ៌មាស និងក្បាច់សន្លឹកភ្ញីពណ៌មាស ដាក់ខ្វែងគ្នា ហើយនៅលើក្បាច់ទាំងពីរនេះ មានរូបសញ្ញាសាលាក្រុង ស្រុក ខណ្ឌពណ៌មាស និងនៅពីលើរូបសាលាក្រុង ស្រុក ខណ្ឌ មានឡេវរូបព្រះរាជសង្ហារពណ៌មាសមួយ ។ បន្ទាប់មកមានបន្ទះក្បាច់ធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញឋាន ។ ផ្ទៃខាងក្រៅនៃក្បាច់ធ្មេញក្របីនេះ មានក្បាច់ខ្សែពួរវេញពណ៌មាសព័ទ្ធជុំវិញបីជាន់ ។

**២-សម្រាប់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ**

សញ្ញាស័ក្តិស្មា សម្រាប់សម្គាល់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានសណ្ឋានដូចសញ្ញាស័ក្តិប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌដែរ ប៉ុន្តែខុសគ្នាត្រង់សញ្ញាស័ក្តិសម្គាល់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានពណ៌ប្រាក់ និងមានក្បាច់ខ្សែពួរវេញពណ៌ប្រាក់ព័ទ្ធជុំវិញពីរជាន់ ។

ខ្នាតសញ្ញាស័ក្តិត្រូវកំណត់ដូចខាងក្រោម ៖

-បាតក្រោម ប្រវែង ០៦សង់ទីម៉ែត្រ

-ទទឹងមុខកាត់ខាងលើ ប្រវែង៤,៤០សង់ទីម៉ែត្រ មានរាងកោង

-បណ្តោយពីលើដល់បាតក្រោម ប្រវែង ១៣សង់ទីម៉ែត្រ ។

**គ-សញ្ញាស័ក្តិចុងដៃអាវទាំងសងខាង**

**១-សម្រាប់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ**

សញ្ញាស័ក្តិចុងដៃអាវទាំងសងខាង សម្រាប់សម្គាល់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានផ្ទៃកម្ទីពណ៌ខ្មៅរចនាគុបតែង ដោយក្បាច់ភ្ញីទេសពណ៌មាស និងមានគួរស្រូវពណ៌មាសនៅខាងចុង ហើយក្បាច់គួរស្រូវមួយទៀតខ្វែងនឹងគល់ក្បាច់ភ្ញីទេស ។ បន្ទាប់មកមានបន្ទះក្បាច់ធ្មេញក្របីពណ៌មាសនៅផ្នែកខាងលើ និងផ្នែកសងខាង ។ ផ្ទៃខាងក្រៅនៃក្បាច់ធ្មេញក្របីនេះ មានខ្សែពួរវេញពណ៌មាសនៅផ្នែកខាងលើ និងផ្នែកចំហៀងទាំងសងខាងបីជាន់ ។ នៅបាតក្រោមបង្អស់នៃសញ្ញាស័ក្តិចុងដៃអាវ មានខ្សែពួរវេញពណ៌មាសមួយ ។

**២-សម្រាប់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ**

សញ្ញាស័ក្តិចុងដៃអាវទាំងសងខាង សម្រាប់សម្គាល់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានសណ្ឋានដូចសញ្ញាស័ក្តិចុងដៃអាវរបស់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌដែរ ប៉ុន្តែខុសគ្នាត្រង់សញ្ញាស័ក្តិចុងដៃអាវសម្គាល់សមាជិកក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ មានពណ៌ប្រាក់ និងមានក្បាច់ខ្សែពួរវេញពណ៌ប្រាក់ ព័ទ្ធជុំវិញពីរជាន់ ។

ខ្នាតសញ្ញាស័ក្តិចុងដៃអាវទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោម ៖

-មានរាងបួនជ្រុងទ្រវែង

-បណ្តោយប្រវែង ៣២សង់ទីម៉ែត្រ

-ទទឹងប្រវែង ១១សង់ទីម៉ែត្រ ។

សញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវទាំងសងខាង មានគំរូដូចក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## អំពីឯកសណ្ឋាន និងការប្រើប្រាស់

**មាត្រា ៥ .-**

ឯកសណ្ឋានសម្រាប់ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានកំណត់ដូចខាងក្រោម ៖

**ក-ឯកសណ្ឋានផ្លូវការ**

**១-ចំពោះបុរស**

- អាវវ៉ារីរ៉ែកខ្មង បើកក ដៃវែង ឬដៃខ្លីពណ៌កាគី មានប៉ូលស្មាសងខាង ។ អាវនេះមានហោប៉ៅ ចំនួន០៤ គឺហោប៉ៅខាងលើពីរ ដេរប៉ះបត់ផ្នត់កណ្តាល ចាប់ផ្នត់មួយមានគំរបរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមពីរដេរបង្កប់មានគំរបរាងចតុកោណកែង ហើយនៅលើគំរបហោប៉ៅទាំងបួននោះមានឡេវពណ៌កាគី ។ អាវនេះមានឡេវ ០៥គ្រាប់ពណ៌កាគី ។

- ខោជើងវែងពណ៌កាគី ថ្នេរបង្កប់ ចង្កេះត មានហោប៉ៅបួន ដោយហោប៉ៅខាងក្រោយពីរដេរបង្កប់ មានគម្របស្លឹកពោធិ៍ និងចំហៀងពីរដេរបង្កប់តាមថ្នេរនៅផ្នែកខាងលើមុខមានភ្លីពីរសងខាង។

- ស្លាកឈ្មោះសម្រាប់ពាក់នៅលើហោប៉ៅខាងស្តាំ មានរាងបួនជ្រុងទ្រវែង ដែលមានបណ្តោយប្រវែង ១០ សង់ទីម៉ែត្រ និងទទឹង ២,៥០សង់ទីម៉ែត្រ ធ្វើពីជ័រវីងថ្លា ផ្ទៃពណ៌ខៀវចាស់ និងមានខ្សែបន្ទាត់ពណ៌មាសទំហំ ០,២៥ សង់ទីម៉ែត្រព័ទ្ធជុំវិញ ។ នៅជួរខាងលើ មានសរសេរនាមត្រកូល និងនាមខ្លួនជាភាសាខ្មែរ ប្រភេទអក្សរមូលពណ៌មាស ទំហំ ៣៣ និងជួរខាងក្រោមមានសរសេរមុខតំណែង ជាភាសាខ្មែរប្រភេទអក្សរមូលពណ៌មាសទំហំ ២៧ ។

- ស្បែកជើងឃ្លុប កខ្លី ពណ៌ខ្មៅ មានចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

**២-ចំពោះនារី**

- អាវរ៉ាវីឆែកខ្នង បើកក ដៃវែង ឬដៃខ្លីពណ៌កាគី មានសណ្ឋានដូចអាវបុរសដែរ ។

- ខោមានសណ្ឋានដូចខោបុរសដែរ ឬសំពត់ហ្សីបបត់ពណ៌កាគី មានសម្រុងលើភ្នែកគោល នៃស្មុងជើង ប្រវែង ពី១០ ទៅ១៥សង់ទីម៉ែត្រ អនុលោមទៅតាមមាឌ និងកំពស់ ។

- ស្លាកឈ្មោះសម្រាប់ពាក់នៅលើហោប៉ៅខាងស្តាំ មានភិនភាគដូចស្លាកឈ្មោះរបស់បុរសដែរ។

- ស្បែកជើង ឃ្លុបមុខក្រោយ ពណ៌ខ្មៅមានកែងធម្មតា។

ឯកសណ្ឋានផ្លូវការសម្រាប់សម្គាល់ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានគំរូដូចក្នុងឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ ។

**ខ-ឯកសណ្ឋានប្រពៃណីជាតិ**

**១-ចំពោះបុរស**

- អាវកុដពណ៌កាគី កត្រង់ ដៃវែង កាត់រាងធំ មានប៉ូលស្មាសងខាង សម្រាប់ដាក់ស័ក្តិ និងគ្មានឆែកខ្នង ។ អាវនេះមានហោប៉ៅចំនួន០៤ គឺហោប៉ៅខាងលើពីរប៉ះចំកណ្តាល ចាប់ផ្នត់មួយ មានគំរបរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគំរបរាងចតុកោណកែង ហើយនៅលើគំរបហោប៉ៅទាំងបួននោះមានឡេវរូបព្រះរាជសង្ហារ ពណ៌មាស ឬពណ៌ប្រាក់ទៅតាម តួនាទី ។ អាវកុដពណ៌កាគីនេះ មានឡេវរូបព្រះរាជសង្ហារចំនួន០៧ពណ៌មាស ឬពណ៌ប្រាក់ទៅតាមតួនាទី ។ នៅចុងដៃអាវទាំងសងខាង មានសញ្ញាស័ក្តិដូចបានរៀបរាប់ខាងលើ ។

- ខោមានសណ្ឋានដូចឯកសណ្ឋានផ្លូវការ ។

- ស្បែកជើងឃ្លុប កខ្លី ពណ៌ខ្មៅ មានចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

**២-ចំពោះស្ត្រី**

- អាវកុដពណ៌កាគី មានសណ្ឋានដូចអាវបុរសដែរ

- ខោ ឬសំពត់មានសណ្ឋានដូចឯកសណ្ឋានផ្លូវការ

- ស្បែកជើង ឃ្លុបមុខក្រោយ ពណ៌ខ្មៅមានកែងធម្មតា ។

ឯកសណ្ឋានប្រពៃណីជាតិសម្រាប់បុរស និងស្ត្រី មានគំរូដូចក្នុងឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យនេះ។

**មាត្រា ៦ .-**

សញ្ញាស័ក្តិ និងឯកសណ្ឋានសម្រាប់ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានអនុញ្ញាតឲ្យសាមីជនប្រើប្រាស់តែក្នុងអាណត្តិប៉ុណ្ណោះ ។

**មាត្រា ៧ .-**

ការប្រើប្រាស់ឯកសណ្ឋានសម្រាប់ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ឯកសណ្ឋានផ្លូវការ ប្រើសម្រាប់ក្នុងឱកាសទទួលគ្រឿងឥស្សរិយយស ទិវាបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗរបស់រដ្ឋ ឬតាមការកំណត់របស់ថ្នាក់ដឹកនាំស្ថាប័ន ។

- ឯកសណ្ឋានប្រពៃណីជាតិ ប្រើសម្រាប់ក្នុងទិវាបុណ្យប្រពៃណីជាតិ និងសាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ឬក្នុងវត្តអារាម ឬទីកន្លែងផ្សេងៗ ។

ឯកសណ្ឋានទាំងពីរប្រភេទខាងលើនេះ ត្រូវស្លៀកពាក់ទៅតាមការកំណត់ក្នុងសេចក្តីអញ្ជើញជាផ្លូវការរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ ឬក្រសួងព្រះបរមរាជវាំង ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា ៨ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវជានិរាករណ៍ ។

**មាត្រា ៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**

នៃអនុក្រឹត្យលេខ១៧៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦
ស្តីពីសញ្ញាសម្គាល់ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

## សញ្ញាសម្គាល់



**ឧបសម្ព័ន្ធទី២**

នៃអនុក្រឹត្យលេខ១២៧ អនក្រ.បក ថ្ងៃទី១៨ ខែ សីហា ឆ្នាំ២០១៦

ស្តីពីសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវ សម្រាប់សម្គាល់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ



សញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវ សម្រាប់សម្គាល់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ



**ឧបសម្ព័ន្ធទី៣**

នៃអនុក្រឹត្យលេខ១៧៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៦
ស្តីពីឯកសណ្ឋានផ្លូវការ សម្រាប់សម្គាល់ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ



**ឧបសម្ព័ន្ធទី៤**

នៃអនុក្រឹត្យលេខ១៧៧អនក្រ.បក ចុះថ្ងៃទី..១៤..ខែ..សីហា..ឆ្នាំ២០១៦

ស្តីពីឯកសណ្ឋានប្រពៃណីជាតិ សម្រាប់សម្គាល់ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

